ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៧ លេខ ០៩

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC

ក ស វ



# Work Activities

ប្រចាំខែកញ្ញា ឆ្នាំ២០១៤



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | លេខទំព័រ |
|---|---|---|
| ១- | សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការកំណត់ស្តង់ដាគោលជាតិលីត្រ និង សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការកំណត់ស្តង់ដាគោលជាតិសីតុណ្ហភាព | ១ |
| ២- | កិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ | ៤ |
| ៣- | ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំខែសីហា ឆ្នាំ២០១៤ | ៦ |
| ៤- | សកម្មភាពដទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១៣ |

### សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី

# ការកំណត់ស្តង់ដាគោលជាតិលីត្រ

### និងសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី

# ការកំណត់ស្តង់ដាគោលជាតិសីតុណ្ហភាព

កាលពីថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៤ នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឌុយ ឆៅ** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌( ECOSOCC ) និង ឯកឧត្តម **ជីវ សុខហាក់** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការកំណត់ស្តង់ដាគោលជាតិលីត្រ និងសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការកំណត់ស្តង់ដាគោលជាតិសីតុណ្ហភាព ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិកនិងមន្ត្រីនៃ ECOSOCC សមាជិកនិងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងឧស្សាហកម្មនិងសិប្បកម្ម។



ការរៀបចំព្រះរាជក្រឹត្យទាំងពីរនេះ គឺអនុលោមតាមមាត្រា៧ មាត្រា៨ និងមាត្រា១១ ជំពូកទី៤ នៃច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា។

ការអនុវត្តច្បាប់មាត្រាសាស្ត្រឲ្យបានម៉ឺងម៉ាត់ សំដៅធានាឲ្យការធ្វើពាណិជ្ជកម្មមានភាពយុត្តិធម៌និងត្រឹមត្រូវ ដែលធ្វើឲ្យការប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្រត្រឹមត្រូវសុចរិត ការពារផលប្រយោជន៍រវាងអ្នកផ្គត់ផ្គង់ និងអ្នកប្រើប្រាស់ទំនិញ ផលិតផល និងសេវាកម្ម។

វិស័យមាត្រាសាស្ត្រ ក៏ជាផ្នែកមួយយ៉ាងសំខាន់ក្នុងការចូលរួមចំណែកអភិវឌ្ឍផ្នែកវិទ្យាសាស្ត្របច្ចេកទេស ដើម្បីភាពរីកចម្រើននៃសេដ្ឋកិច្ចជាតិ សេដ្ឋកិច្ចតំបន់ និងសេដ្ឋកិច្ចពិភពលោក។ ជាក់ស្តែង កម្ពុជាក៏បានចូលជាសមាជិកពេញសិទ្ធិក្នុងអង្គការអន្តរជាតិមួយចំនួន ដែលពាក់ព័ន្ធនឹងវិស័យមាត្រាសាស្ត្រ រួមមាន៖

-ជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការពិគ្រោះយោបល់ផ្នែកស្តង់ដា និងគុណភាពនៃក្រុមការងារនីត្យានុកូលមាត្រាសាស្ត្រ ACCSQ/WG3 ( ASEAN Consultative Committee for Standards and Quality / WORKING GROUP ON LEGAL METROLOGY )។



-ជាសមាជិកពេញសិទ្ធិនៃអង្គការកម្មវិធីមាត្រាសាស្ត្រអាស៊ីប៉ាស៊ីហ្វិក APMP (ASIA-Pacific Metrology Program)។

-ជាសមាជិកសង្កេតការណ៍ (Correspondent Member) នៃអង្គការអន្តរជាតិនីត្យានុកូលមាត្រាសាស្ត្រ OIML (International Organization of Legal Metrology)។

១.ប្រវត្តិនៃបំពង់ក្រឹតគំរូចំណុះ១លីត្រ៖

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានធ្វើកិច្ចសហប្រតិបត្តិការជាមួយអង្គការសហប្រជាជាតិអភិវឌ្ឍន៍ឧស្សាហកម្ម (UNIDO) និងគោរពតាមលំដាប់ឋានុក្រមផ្នែកសីតុណ្ហភាពនៃអង្គការនីត្យានុកូលភាពមាត្រាសាស្ត្រអន្តរជាតិ (OIML) និងការិយាល័យអន្តរជាតិផ្នែកទម្ងន់និងរង្វាស់រង្វាល់ (BIPM)។ ក្រោយពីមានកិច្ចសហប្រតិបត្តិការដូចខាងលើ ក្នុងគម្រោងដំណាក់កាលទី១ ពីឆ្នាំ២០០៣-២០០៥ អង្គការសហប្រជាជាតិអភិវឌ្ឍន៍ឧស្សាហកម្ម បានផ្តល់នូវបំពង់ក្រឹតគំរូចំណុះ ១លីត្រ ផលិតនៅប្រទេសអាល្លឺម៉ង់ ពីវត្ថុធាតុកញ្ចក់ពិសេសធន់នឹងបម្រែបម្រួលសីតុណ្ហភាពក្តៅខ្លាំង និងត្រជាក់ខ្លាំងភ្លាមៗ។ ដោយការពិនិត្យលើលក្ខណៈបច្ចេកទេស ក្រសួងឧស្សាហកម្ម និងសិប្បកម្ម សម្រេចជ្រើសរើសយកបំពង់ក្រឹតមានលេខសម្គាល់ ៣៣ ជាស្តង់ដាគោលជាតិលីត្រ ដោយឈរលើមូលដ្ឋានដូចខាងក្រោម៖

-លទ្ធផលព្យាសកម្មលើកដំបូងកម្រិតលំអៀង +0,០២៧ ml នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៥ ដោយមន្ទីរពិសោធន៍ PTB នៃប្រទេសអាល្លឺម៉ង់។

-លទ្ធផលព្យាសកម្មលើកទី២ កម្រិតលំអៀង +0,០១៦ ml នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៣ ដោយមន្ទីរពិសោធន៍ National Metrology Center នៃប្រទេសកម្ពុជា។

-រូបរាងបំពង់ក្រឹតគំរូ អនុលោមត្រឹមត្រូវតាមបទបញ្ញាបច្ចេកទេស និងវត្ថុធាតុផ្សំ ដោយអនុលោមត្រឹមត្រូវតាមបទបញ្ញាបច្ចេកទេសរបស់អង្គការ OIML នៃកញ្ចក់ពិសេសធន់នឹងបម្រែបម្រួលសីតុណ្ហភាពក្ដៅខ្លាំង និងត្រជាក់ខ្លាំងភ្លាមៗ។

២.ប្រវត្តិនៃសីតុណ្ហម៉ែត្រ៖

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានធ្វើកិច្ចសហប្រតិបត្តិការជាមួយអង្គការសហប្រជាជាតិអភិវឌ្ឍន៍ឧស្សាហកម្ម(UNIDO) និងគោរពតាមលំដាប់ឋានុក្រមផ្នែកសីតុណ្ហភាពនៃអង្គការនីត្យានុកូលភាពមាត្រាសាស្ត្រអន្តរជាតិ (OIML) និងការិយាល័យអន្តរជាតិផ្នែកទម្ងន់និងរង្វាស់រង្វាល់ (BIPM)។ ក្រោយពីមានកិច្ចសហប្រតិបត្តិការដូចខាងលើ ក្នុងគម្រោងដំណាក់កាលទី២ ពីឆ្នាំ២០០៦-២០០៩ អង្គការសហប្រជាជាតិអភិវឌ្ឍន៍ឧស្សាហកម្ម បានផ្ដល់នូវសីតុណ្ហភាពម៉ែត្រផលិតនៅសហរដ្ឋអាម៉េរិក ដែលសំបកជាវត្ថុធាតុកញ្ចក់ពិសេស និងមានរេស៊ីស្តង់ធ្វើពីប្លាទីន ចំនួន ២គ្រឿង។ ដោយការពិនិត្យលើលក្ខណៈបច្ចេកទេស ក្រសួងឧស្សាហកម្ម និងសិប្បកម្ម សម្រេចជ្រើសរើសយកសីតុណ្ហម៉ែត្រមានលេខសម្គាល់ ១៥០៣ ជាស្តង់ដាគោលជាតិសីតុណ្ហភាព ដោយឈរលើមូលដ្ឋានដូចខាងក្រោម៖

-លទ្ធផលព្យាសកម្មលើកដំបូងចាប់ពីសីតុណ្ហភាព -២០០ 0c (អង្សាសេ) តាមលំដាប់រហូតដល់ +៦៦០ 0c (អង្សាសេ) នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៦ ដោយមន្ទីរពិសោធន៍ NVLAP នៃសហរដ្ឋអាមេរិក។

-លទ្ធផលព្យាសកម្មលើកទី២ នៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៤ ដោយមន្ទីរពិសោធន៍ NIMT នៃប្រទេសថៃ។

-រូបរាងសីតុណ្ហម៉ែត្រ អនុលោមត្រឹមត្រូវតាមបទបញ្ញាបច្ចេកទេស និងវត្ថុធាតុផ្សំ ដោយអនុលោមត្រឹមត្រូវតាមបទបញ្ញាបច្ចេកទេសរបស់អង្គការ OIML[១]។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្ដីព្រាងឯកសារនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្ដីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្ដីព្រាងនេះទាំងស្រុង។

(១) អត្ថបទនេះដកស្រង់ពីសេចក្ដីព្រាងសេចក្ដីថ្លែងហេតុនៃសេចក្ដីព្រាងព្រះរាជក្រឹត្យស្ដីពីការកំណត់ស្តង់ដាគោលជាតិលីត្រ និងសេចក្ដីព្រាងព្រះរាជក្រឹត្យស្ដីពីការកំណត់ស្តង់ដាគោលជាតិសីតុណ្ហភាព។

# កិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ

កាលពីថ្ងៃអង្គារ៍ ទី៣០ ខែកញ្ញា ឆ្នាំ២០១៤ នៅវេលាម៉ោង១៦:00 នាទីរសៀលនៅទីស្ដីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំត្រួតពិនិត្យចុងក្រោយ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្ដម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ដោយមានការអញ្ជើញចូលរួមពីឯកឧត្ដម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ចសង្គមកិច្ច និងវប្បធម៌ (ECOSOCC) ឯកឧត្ដម អនុប្រធាន និងសមាជិក ECOSOCC ក្រុមប្រឹក្សាអ្នកច្បាប់ ឯកឧត្ដម **សយ សុខា** អគ្គលេខាធិការរាជរដ្ឋាភិបាល ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** ក្រសួងសាមី និងតំណាងក្រសួងពាក់ពន្ធ័ ដើម្បីពិនិត្យពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖

១-សេចក្ដីព្រាងព្រះរាជក្រឹត្យស្ដីពីការកំណត់ស្តង់ដាគោលជាតិលីត្រ និងសេចក្ដីព្រាងព្រះរាជក្រឹត្យស្ដីពីការកំណត់ស្តង់ដាគោលជាតិសីតុណ្ហភាព

២-បញ្ហាផ្សេងៗ៖ កិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលស្ដីពីផៃស្ងួតក្នុងក្របខណ្ឌគណៈកម្មការសេដ្ឋកិច្ច និងសង្គមសម្រាប់តំបន់អាស៊ីប៉ាស៊ីហ្វិក អង្គការសហប្រជាជាតិ (UNESCAP)។

ជាកិច្ចចាប់ផ្ដើមឯកឧត្ដម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រីបានលើកឡើងពីភាពចាំបាច់ និងសារៈសំខាន់នៃសេចក្ដីព្រាងព្រះរាជក្រឹត្យស្ដីពីការកំណត់ស្តង់ដាគោលជាតិលីត្រ ដែលជាយន្តការក្នុងការត្រួតពិនិត្យដើម្បីឲ្យមានភាពត្រឹមត្រូវយុត្តិធម៌។

បន្ទាប់ពី ឯកឧត្ដម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធាន ECOSOCC បានធ្វើអន្តរាគមនិងផ្ដល់មតិមួយចំនួនរួចមក អង្គប្រជុំបានឯកភាពកែសម្រួលសេចក្ដីព្រាងព្រះរាជក្រឹត្យទាំងពីរនេះដូចតទៅ៖



១-សេចក្ដីព្រាងព្រះរាជក្រឹត្យស្ដីពីការកំណត់ស្តង់ដាគោលជាតិលីត្រ និងសេចក្ដីព្រាងព្រះរាជក្រឹត្យស្ដីពីការកំណត់ស្តង់ដាគោលជាតិសីតុណ្ហភាព

១-១.ករណីសេចក្ដីព្រាងព្រះរាជក្រឹត្យស្ដីពីការកំណត់ស្តង់ដាគោលជាតិលីត្រ

អង្គប្រជុំបានកែសម្រួលក្នុងមាត្រា១ បន្ទាត់ទី៦ ដោយបន្ថែមពាក្យ "បំពង់ក្រិតធ្វើអំពី" ពីមុខពាក្យ "កញ្ចក់"។

១-២.ករណីសេចក្ដីព្រាងព្រះរាជក្រឹត្យស្ដីពីការកំណត់ស្តង់ដាគោលជាតិសីតុណ្ហភាព

អង្គប្រជុំបានកែសម្រួលខ្លឹមសារមួយចំនួនដូចខាងក្រោម៖

-ប្តូរពាក្យ "សីតុណ្ហម៉ែត្រ" ទៅជា "សីតុណ្ហមាត្រ"

កែសម្រួលការរៀបចំអត្ថបទក្នុងមាត្រា១ ដោយយកគំរូលំដាប់លំដោយតាមព្រះរាជក្រឹត្យស្តីពីការកំណត់ស្តង់ដាគោលជាតិគីឡូក្រាម។

២-សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលស្តីពីផែស្ងួតក្នុងក្របខណ្ឌគណៈកម្មការសេដ្ឋកិច្ចនិងសង្គមសម្រាប់តំបន់អាស៊ីប៉ាស៊ីហ្វិកអង្គការសហប្រជាជាតិ (UNESCAP)

អង្គប្រជុំបានសម្រេចឲ្យអគ្គលេខាធិការរាជរដ្ឋាភិបាល អញ្ជើញក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ ក្រសួងសាធារណការនិងដឹកជញ្ជូន និងស្ថាប័នដែលពាក់ព័ន្ធ ដើម្បីចូលរួមប្រជុំចង្អៀតធ្វើការពិភាក្សាទៅលើកិច្ចព្រមព្រៀងនេះ។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង១៧:៥០នាទី ក្រោមបរិយាកាសរីករាយ ស្និតស្នាល និងទទួលបានលទ្ធផលវិជ្ជមានតាមការរំពឹងទុក។



# ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែសីហា ឆ្នាំ២០១៤*



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា**ប្រចាំខែកក្កដា ឆ្នាំ២០១៤**នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៤ ដឹកនាំដោយ ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមសមាជិក សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ នាខែសីហាឆ្នាំ២០១៤ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់កើនឡើង ០,៣% ធៀបនឹងខែមុននិងកើនឡើង ៤,១% ធៀបនឹងខែដូចគ្នាឆ្នាំមុន (រយៈពេល១២ខែ)។

តារាង១.១ .បម្រែបម្រួលថ្លៃធៀបនឹងខែដូចគ្នាឆ្នាំមុនសម្រាប់ក្រុមទំនិញមួយចំនួន

| ក្រុមទំនិញ: | | មុខទំនិញ: | |
|---|---|---|---|
| គ្រឿងសង្ហារិម និងសម្ភារៈប្រើប្រាស់ : | +៦,៧% | ផ្លែឈើ: | +១២,៤% |
| ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់: | +៦៦%, | សាច់ជ្រូក : | +១១,១% |
| ភោជនីយដ្ឋាន : | +៦,១% | សាច់គោស្រស់ : | +៧,៣% |
| ម្ហូបអាហារ និងភេសជ្ជៈមិនមានជាតិស្រវឹង | +៥៦%, | ឧស្ម័នៈ | +៥,៦% |

តារាង១.២២០១២ ប្រើប្រាស់សន្ទស្សន៍ថ្លៃទំនិញបម្រែបម្រួល .–២០១៤

| ឆ្នាំ | ធៀបនឹងខែ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា^P | តុលា^P | វិច្ឆិកា^P | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៤ | ដូចគ្នាឆ្នាំមុន | ៤៥%, | ៤,៣% | ៥,០% | ៤,៩% | ៤,៦% | ៤,៩% | ៤២%, | ៤១%, | ៤០%, | ៤០%, | ៣៩%, | | |
| | មុន | ០២,% | ០ | ០,៥% | ០,៥% | ០៣,% | ០៥,% | ០៤%, | ០៣%, | ០៦%, | ០២%, | -០,៣% | | |
| ២០១៣ | ដូចគ្នាឆ្នាំមុន | ១៨%, | ១,៧% | ១,០% | ១,០% | ២,៨% | ២,៩% | ៤,០% | ៣,៣% | ៣,៩% | ៤,២% | ៤,១% | ៤,៧% | ៣០%, |
| | មុន | ០៣,% | ០,២% | ០-,១% | ០,៦% | ០,៧% | ០,២% | ១% | ០,៤% | ០,៧% | ០២%, | -០,៣% | ០,៥% | |
| ២០១២ | ដូចគ្នាឆ្នាំមុន | ៥៨%, | ៥៤%, | ៥៤%, | ៤៨%, | ២២%, | ១៨%, | ១៣%, | ២,២% | ១,៤% | ១,២% | ១,៦% | ២៦%, | ២,៩% |
| | មុន | ១០,% | ០៤,% | ០៦%, | ០៥%, | -១១%, | ០១%, | ០% | ១,១% | ០,២% | ០-,២% | ០-,២% | ០% | |

P: តួលេខខែ កញ្ញាតុលា និងវិច្ឆិកា ឆ្នាំ២០១៤ ជាតួលេខព្យាករដោយយក តាមវិធីសាស្ត្រ) .វ.ស.វ. DECOMPOSITION)

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់ទេ (មើលតារាងភ្ជាប់មកជាមួយ)។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ )Excel) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

ក្រាហ្វ ១១.. ចលនានិងបម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់




តារាង១.៣ .អត្រាប្តូរប្រាក់

| ប្រភេទ | សីហា២០១៤ | កក្កដា២០១៤ | សីហា២០១៣ | ប្រភេទ | សីហា២០១៤ | កក្កដា២០១៤ | សីហា២០១៣ |
|---|---|---|---|---|---|---|---|
| **៛/ដុល្លារ** | ៤០៦៥៛/១$ | ៤០៥០៛/១$ | ៤០៦២៛/១$ | **បាត/ដុល្លារ** | ៣១,៩៣បាត/១$ | ៣១,៩៤បាត/១$ | ៣១,៤១បាត/១$ |
| **៛/បាត** | ១២៧៛/១បាត | ១២៧៛/១បាត | ១២៩៛/១បាត | **ដុង/ដុល្លារ** | ២១១៧០ដុង/១$ | ២១២២០ដុង/១$ | ២១៣០០ដុង/១$ |
| **៛/ដុង** | ០,១៩២៛/១ដុង | ០,១៩១៛/១ដុង | ០,១៩១៛/១ដុង | | | | |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់រតនាគារជាតិអគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារក្នុងខែសីហាឆ្នាំ២០១៤ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម:

**២.១. ចំណូលថវិកាជាតិ** : អនុវត្តបាន៨២៥៦.ពាន់លានរៀល៩៩ខែប្រចាំមធ្យម)% នៃផែនការក្នុងនោះ(ចំណូលចរន្តចំនួន ៨១៩,៧ពាន់លានរៀលប្រចាំមធ្យម)ខែ ១០៣នៃ % ៦និងចំណូលមូលធន(ផែនការ,០ពាន់លានរៀល។

➢បើធៀបនឹងខែមុនចំណូលថវិកាជាតិថយចុះ៧,៩% ប៉ុន្តែកើនឡើង២០៦,%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢នៅក្នុងចំណូលចរន្ត:

✓ចំណូលសារពើពន្ធមានចំនួន ៧២៤ពាន់លានរៀល៩, ថយចុះ៦១,%ធៀបនឹងខែមុនប៉ុន្តែកើនឡើង៣៤៨,% ធៀបនឹងខែដូចគ្នាឆ្នាំមុន ។

ក្រាហ្វ ២១.. ចំណូលថវិកាជាតិ ឆ្នាំ ២០១២–២០១៤ (ពាន់លានរៀល)




✓ចំណូលមិនមែនសារពើពន្ធមានចំនួន ៩៤ ពាន់លានរៀល៧,ថយចុះ២១៦,% ធៀបនឹងខែមុននិងថយចុះ១៤៩.% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

**តារាង២.១. មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ**

| ចំណូលសារពើពន្ធ (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | | ចំណូលមិនមែនសារពើពន្ធ (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ:+០,៥% | (+៣៩,៥%) | ➢ នេសាទ:-៨,៩% | (+៩,២%) |
| ➢ ចំណូលពន្ធដារ: +៨,៣% | (+៤២,៦%) | ➢រុក្ខាប្រមាញ់:+២៧,៦% | (-៧៩,៦%) |
| ➢ ចំណូលសារពើពន្ធផ្សេងៗ:-២៧,៣% | (-៤,១%) | ➢សម្បទានរ៉ែ:+១៧៩,៨% | (-៤,៤%) |
| ✧ កាស៊ីណូ : -៤០,៣% | (+២,៨%) | ➢ អាកាសចរណ៍ស៊ីវិល:+១០០៧,៧% | (+២៧,១%) |
| ✧ អាជ្ញាបណ្ណក្នុងស្រុក : -៨១,៧% | (-៥១,៩%) | ➢ផលទុននៃសកម្មភាពទេសចរណ៍: -១២,៦% | (-៣,៤%)) |
| ✧កម្រៃគ្រប់គ្រងនិងទិដ្ឋាការនាំចេញ : -៧,១% | (-៦,៣%) | ➢ប្រៃសណីយ៍ និងទូរគមនាគមន៍:+៦៨៥,៤% | (-២១,៦%) |
| | | ➢អាករស្ថានទូត(លិខិតឆ្លងដែន និងទិដ្ឋាការ): -៧,៨% | (-៣៨,៥%) |
| | | ➢ចំណូលផ្សេងៗទៀតពុំមែនសារពើពន្ធ:-៧៩,១% | (+៨,៥%) |

**២.២. ចំណាយថវិកាជាតិ**:អនុវត្តបាន ៧១៩,៧ពាន់លានរៀល(*មធ្យមប្រចាំខែ ៥៣% នៃផែនការ*) ក្នុងនោះ ចំណាយចរន្ត ចំនួន ៥៧០,៨ពាន់លានរៀល (*មធ្យមប្រចាំខែ ៧៣% នៃផែនការ*) និងចំណាយមូលធនចំនួន១៤៨,៩ពាន់លានរៀល។

➢ *បើធៀបនឹងខែមុន*ចំណាយថវិកាជាតិថយចុះ ១៨ ១%,ប៉ុន្តែកើនឡើង៣០%ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះចំណាយចរន្តថយចុះ ២០៣%, ធៀបនឹងខែមុនប៉ុន្តែកើនឡើង៣៩៨,%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

**២.៣. សមតុល្យថវិកាជាតិ** : ថវិកាជាតិនាខែនេះមាន អតិរេកចំនួន **១០៦**ពាន់លានរៀល។

ក្រាហ្វ២.២២០១ ចំណាយថវិកាជាតិ ឆ្នាំ .២–២០១៤
(ពាន់លានរៀល)




## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែសីហាឆ្នាំ២០១៤មានលក្ខណៈដូចខាងក្រោម:

➢រូបិយវត្ថុ$M_2$ មានចំនួន៣៩៩៧៨ពាន់លានរៀល កើនឡើង១%ធៀបនឹងខែមុន និងកើនឡើង៣៧,២ %ធៀបនឹងខែដូចគ្នាឆ្នាំមុន។**កំណើន$M_2$** ជារួម បណ្តាលមកពីកំណើនប្រាក់បញ្ញើចរន្ត រូបិយវត្ថុក្រៅធនាគារនិងប្រាក់បញ្ញើជារូបិយបណ្ណ។

➢ក្នុងខែនេះ ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារមានចំនួន១៦២%,និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន៨៣៨%, នៃរូបិយវត្ថុ$M_2$។

ក្រាហ្វ៣១.. សមាសធាតុរូបិយវត្ថុខែសីហា ឆ្នាំ២០១៤




តារាង៣.១ .សមាមាត្រចំនួនប្រាក់រៀល នៅក្នុងរូបិយវត្ថុ $M_2$ ឆ្នាំ២០១៤

| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារ | ១៧,៧% | ១៨,០% | ១៧,៧% | ១៧,៦% | ១៧២%, | ១៦០,% | ១៦,២% | ១៦,២% | | | | |
| ប្រាក់រៀលក្រៅធនាគារ | ១៣៤%, | ១៣៥%, | ១៣,៨% | ១៣,៨% | ១៣២%, | ១២,២% | ១២,៣% | ១២៤%, | | | | |

ក្រាហ្វ៣២..បម្រែបម្រួលសមាសធាតុរូបិយវត្ថុខែសីហា២០១៤ :ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន



➢ **ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ**មានចំនួន ៤០៥៩លានដុល្លារកើនឡើង០,១%ធៀបនឹងខែមុន និងកើនឡើង ១៩,១ %ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ*** ក្នុងខែនេះមានចំនួន ១៣៣០៩ ពាន់លានរៀលកើនឡើង ២២%, ធៀបនឹងខែមុន និងកើនឡើង៧៦,៨%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៣.២.ការផ្តល់ឥណទាននិងអត្រាការប្រាក់ប្រចាំឆ្នាំ

| *ផ្តល់ដោយ* | *សីហា២០១៤* | *កក្កដា២០១៤* | *សីហា២០១៣* |
|---|---|---|---|
| ឥណទានផ្តល់ដោយធនាគារពាណិជ្ជ(ពាន់លានរៀល) | ៣៥០៣៤ | ៣៤០២៨ | ២៧៦៦៦ |
| ក្នុងនោះ ជារៀល | មិនទាន់មានតួលេខ | មិនទាន់មាន | ៤២៩ |
| ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(ពាន់លានរៀល) | មិនទាន់មានតួលេខ | ៦៨០៩ | ៤៥៤៥ |
| អត្រាការប្រាក់បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៥៩៣%, | ៥,៨៧% | ៥,៩៤% |
| អត្រាការប្រាក់កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១៦៤%, | ១៦,១២% | ១១,៩៣% |
| អត្រាការប្រាក់បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤២៣%, | ៤,២៣% | ៤,៣៩% |
| អត្រាការប្រាក់កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១១៥១%, | ១១,៥១% | ១១,៣៧% |

## ៤) ស្ថានភាពកសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➡ក្នុងខែសីហាឆ្នាំ២០១៤ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម:

➢**កសិកម្ម**:

✓នេសាទសម្រេចបាន៤២ពាន់តោន កើនឡើង១៧%ធៀបនឹងខែមុន ប៉ុន្តែថយចុះ១៨%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢**ឧស្សាហកម្ម**:

✓ អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន៤០៧៦,GWHមានការកើនឡើង៥%ធៀបនឹងខែមុន និង កើនឡើង២៤%ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះផ្គត់ផ្គង់ដោយវារីអគ្គសនីមានចំនួន ៣១៣៨, GWHមានការ កើនឡើង១១%ធៀបនឹងខែមុន និងកើនឡើង៧៨%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

✓ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន៤៨៧,៦ លានដុល្លារ មិនមានការប្រែប្រួលបើធៀបនឹងខែមុន ប៉ុន្តែ មានការកើនឡើង១%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៤.១ .ការចុះបញ្ជីរោងចក្រ និងឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម

| *ប្រភេទ* | *ចំនួន –សីហា២០១៤* | *ចំនួន–កក្កដា២០១៤* | *ចំនួន–សីហា២០១៣* |
|---|---|---|---|
| ▪រោងចក្រថ្មីដែលបានចុះបញ្ជី | ១២ | ២៨ | ២៣ |
| ▪ ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១២២៨ | ១២១៦ | ១០២៦ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ១៧ | ៨ | ២៧ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | — | — | ៨ |

➢**សំណង់** (ការអនុញ្ញាត):

✓សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ៤៩០,១ពាន់ម$^2$កើនឡើង៣២៧%ធៀបនឹងខែមុននិងកើនឡើង៣២% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹង ១៥៣លានដុល្លារ កើនឡើង ៣៦៤% ធៀបនឹងខែមុន និង កើនឡើង៥៤%ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន:

តារាង៤.២ .សំណង់អនុញ្ញាតតាមប្រភេទផ្សេងៗ

| ប្រភេទ | ពាន់ម$^2$ —សីហា២០១៤ | ពាន់ម$^2$ —កក្កដា២០១៤ | ពាន់ម$^2$ —សីហា២០១៣ |
|---|---|---|---|
| ▪ លំនៅឋាន | ២៤៨៥, | ៤៥,២ | ១៣៧,០ |
| ▪ ឧស្សាហកម្ម | ១៩៤,៨ | ២៤,១ | ១៨៥,៧ |
| ▪ទេសចរណ៍ | ១៨៤, | ១៥៧, | ៨,១ |
| ▪ផ្សេងៗ | ១៦,៩ | ២៤,៤ | ២៥,២ |
| អនុញ្ញាតសរុប | ៤៩០១, | ១១៤,៩ | ៣៧១៨, |

✓ដូច្នេះសំណង់អនុញ្ញាតដែលពេញនិយមនាខែនេះគឺលំនៅឋាន៥០៣៩ និងឧស្សាហកម្ម ៧%,,៧%នៃផ្ទៃ ក្រឡាសរុប។

**➢ការងារ**

តារាង៤.៣ការ .ស្វែងរកការងារនិងទទួលបានការងារ

| ប្រភេទ | នាក់—សីហា២០១៤ | នាក់—កក្កដា២០១៤ | នាក់—សីហា២០១៣ |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារ ( ការងារទីភ្នាក់ងារជាតិមុខរបបនិង) | ១៥៧០ | ១៨៨៨ | NA |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ៩៦០៦ | ៩៣៧០ | ២០៥៤ |
| អ្នកទទួលបានការងារក្នុងប្រទេស | ៧៦០៨ | ៦៧២៩ | ៩៥១ |
| អ្នកទទួលបានការងារក្រៅប្រទេស | ១៩៩៨ | ២៦៤១ | ១១០៣ |

**➢វិនិយោគ**

តារាង៤.៤.គម្រោងវិនិយោគអនុញ្ញាតដោយគ(ថ្មីនិងពង្រីក) .ក.អ.ក/.ក.វ.

| ប្រភេទ | សីហា២០១៤ | កក្កដា២០១៤ | សីហា២០១៣ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ១៦៣៣, | ២៤១,១ | ៣៨២,៩ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ៣១៥, | ៣២,៧ | ២៧, |
| វិស័យឧស្សាហកម្ម (ក្នុងរង្វង់ក្រចកជាតួលេខ នៃតំបន់សេដ្ឋកិច្ចពិសេស) | ៨៧៨, (៨,៩) | ៥៦,២ (៥,២) | ១២០,៣ (—) |
| វិស័យទេសចរណ៍ | ០ | ១២ | ០ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ៤៣៩, | ១៤០,២ | ២៥៩៩, |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ២៤ | ១៨ | ១៥ |
| បង្កើតការងារ (ពាន់នាក់) | ២៥១, | ១៨៨, | ១៤៣, |

**➢សេវាកម្ម**

តារាង៤.៥.ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម

| ប្រភេទ | ចំនួន —សីហា២០១៤ | ចំនួន—កក្កដា២០១៤ | ចំនួន—សីហា២០១៣ |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ៤០០ | ៣៤៨ | ៣១៨ |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ១០ | ២ | ៣ |
| ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | NA | ៣៨៨ | ២៨២ |

➢**ទំនិញឆ្លងកាត់កំពង់ផែ**(កំពង់ផែ៥សរុប) មានចំនួន៦១៤ពាន់តោន២,កើនឡើង២%ធៀបនឹងខែមុនប៉ុន្តែថយចុះ ១៣% ធៀបនឹងខែដូចគ្នាឆ្នាំមុនក្នុងនោះ:

តារាង៤.៦.ទំនិញឆ្លងកាត់កំពង់ផែផ្សេងៗ (ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន)

| | | | |
|---|---|---|---|
| ▪ កំពង់ផែភ្នំពេញ:៣៥%- | (១៤%-) | ▪ កំពង់ផែស្រែអំបិល និងកោះកុង:១២%- | (៣៩%-) |
| ▪ កំពង់ផែកំពង់សោម:+៧% | (៣%-) | ▪ កំពង់ផែឧកញ៉ាម៉ុង: +១២៣% | (៥%-) |

➢ **ការធ្វើដំណើរតាមផ្លូវអាកាសនិងទេសចរណ៍**

តារាង៤.៧.អ្នកដំណើរតាមផ្លូវអាកាសនិងទេសចរណ៍

| *ប្រភេទ* | *ចំនួន)ពាន់នាក់(* | *%∆ ធៀបនឹងខែមុន* | *%∆ធៀបនឹងខែដូចគ្នាឆ្នាំមុន* |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ១០,៩ | +៤៥% | +៣៦% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ២១,២ | +៥% | +២៥% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៤២៧,៨ | +១១% | +២០% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ៨១៤, | ៥%- | +១៧% |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា | ៣៤៧១, | +២% | +២% |
| ✓ តាមផ្លូវអាកាស | ១៧៩៧, | +៦% | +១៧% |
| ✓ តាមផ្លូវគោក និងទឹក | ១៦៧៦, | ២%- | ១១%- |

## ៥) ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

➡ពីប្រភពអគ្គនាយកដ្ឋានគយនិងរដ្ឋាករ ការនាំចូលនាខែសីហាមានចំនួន ៣៦១១,៤ពាន់លានរៀល (ស្មើនឹង៩០២.៨ លានដុល្លារ ស.រ.អា.)កើនឡើង៣,៤%ធៀបនឹងខែមុននិងកើនឡើង១២,៨%ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះ :

តារាង៥.១បម្រែបម្រួលនៃការនាំចូលមុខទំនិញមួយចំនួន.

| ទំនិញ | %∆ធៀបនឹងខែមុន | %∆ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %∆ធៀបនឹងខែមុន | %∆ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | +២១,៤% | +១៣,៧% | រថយន្តសរុប (រ.ល.៣) | +៤,៥% | +៥៣,២% |
| ប្រេងម៉ាស៊ូត | -៦,៧% | -៧,៧% | រថយន្តសរុប (គ្រឿង) | +៧៤%, | +៥៤,៥% |
| ឧស្ម័ន | +២៧,៤% | +៦,0% | ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | +៣១%, | +៥៤% |
| អគ្គិសនីនាំចូល | -១១% | -៦៤,៦% | ម៉ូតូ (គ្រឿង) | | |
| ដែកសំណង់ | -១៧,១% | +៥៤,២% | អង្ករ | -១៧,៩% | -៥៥,៩% |
| ស៊ីម៉ង់ត៍ | +១២,៦% | +៤៤% | ផ្លែឈើនិងបន្លែ | -១៧,៥% | +១៨៨,៨% |
| គ្រឿងអេឡិចត្រូនិក | | | ជីនិងថ្នាំកសិកម្ម | +៣,៨% | +៣៣,៣% |
| | | | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | -១៥,៩% | -៥,៩% |

➡ **ការនាំចេញ** ខែសីហាឆ្នាំ២០១៤ មានចំនួន ៣៣២២,៣ពាន់លានរៀល ស្មើនឹង៨៣០,៦លានដុល្លារ ស.រ.អា. (៩២% នៃការនាំចូល)កើនឡើង១២,៦%ធៀបនឹងខែមុន និងកើនឡើង៧,៧%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៥.២បម្រែបម្រួលនៃការនាំចេញមុខទំនិញមួយចំនួន.

| *ទំនិញ* | *%∆ធៀបនឹងខែមុន* | *%∆ធៀបនឹងខែដូចគ្នាឆ្នាំមុន* | *ទំនិញ* | *%∆ធៀបនឹងខែមុន* | *%∆ធៀបនឹងខែដូចគ្នាឆ្នាំមុន* |
|---|---|---|---|---|---|
| ផលិតផលឈើកែច្នៃ | ២៧%- | +២២,៦% | ផលិតផលនេសាទ | ១០-,៨% | ៥១-,២% |
| វាយនភណ្ឌនិងស្បែកជើង | +១៤,៧% | +១,២% | កៅស៊ូ | ៦-,៥% | ១១-,២% |
| អង្ករ | +៣៥,៥% | +៩,៦% | | | |

➡ក្នុងខែសីហានេះជញ្ជីងពាណិជ្ជកម្មមានឱនភាពចំនួន ២៨៩,១ពាន់លានរៀលស្មើនឹង៧២ដុល្លារ សលាន៣,.រ.អា.។

## ៦) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែសីហាឆ្នាំ២០១៤នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច នៃព្រះរាជាណាចក្រកម្ពុជាបង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចក្នុងតារាងខាងក្រោម :

**តារាង ៦.១.** សូចនាករសេដ្ឋកិច្ច សង្គមកិច្ច ដែលមានការប្រែប្រួលគួរឲ្យចាប់អារម្មណ៍

| ល.រ. | សូចនាករ | ធៀបនឹងខែដូចគ្នាឆ្នាំមុន | កំណត់សម្គាល់ |
|---|---|---|---|
| ១ | ថ្លៃសាច់ជ្រូក | +១១១%, | — |
| ២ | ថ្លៃផ្លែឈើ | +១២៤%, | — |
| ៣ | ចំណូលពីរុក្ខាប្រមាញ់ | –៧៩៦%, | ជាមុខចំណូលក្នុងចំណូលមិនមែនសារពើពន្ធ |
| ៤ | អាករស្ថានទូត(លិខិតឆ្លងដែននិងទិដ្ឋាការ) | –៣៨៥%, | ជាមុខចំណូលក្នុងចំណូលមិនមែនសារពើពន្ធ |
| ៥ | ទុនវិនិយោគអនុញ្ញាតដោយក.ក.អ. | –៥៧% | ជាទុនវិនិយោគផ្ទាល់ពីបរទេស)FDI( |
| ៦ | នាំចូលរថយន្តសរុប (គិតជាសាច់ប្រាក់) | +៥៣២%, | — |
| ៧ | នាំចូលផ្លែឈើនិងបន្លែ | +១៨៨៨%, | — |

## ៧) សេចក្តីសន្និដ្ឋាន

*អង្គប្រជុំបានពិភាក្សាបញ្ហាមួយចំនួនដូចខាងក្រោម:*

១) **ស្ថានភាពថ្លៃ**:ជារួមក្នុងខែសីហាអត្រាសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់តិចជាង ៥% ធៀបនឹងខែដូចគ្នាឆ្នាំមុនប៉ុន្តែមុខទំនិញដូចជា សាច់ជ្រូក បន្លែនិងផ្លែឈើ នៅតែមានការឡើងថ្លៃខ្ពស់។

២)**សំណង់**:ក្នុងខែសីហាឆ្នាំ ២០១៤សំណង់អនុញ្ញាតមានការកើនឡើងគួរឲ្យចាប់អារម្មណ៍ជាពិសេសសំណង់លំនៅឋាននិងឧស្សាហកម្ម។មានការកត់សម្គាល់ថាគុណភាពសំណង់នៅមានកម្រិតដូចជាមានការជ្រាបទឹក ប្រេះស្រាំនិងប្រព័ន្ធលូមិនសូវល្អជាដើម។ **បញ្ហានេះតម្រូវឲ្យមានលិខិតបទដ្ឋានគតិយុទ្ធស្តីពីសំណង់ច្បាស់លាស់ដើម្បីជាយន្តការ: (ក) កំណត់ការទទួលខុសត្រូវរបស់ក្រុមហ៊ុនសាងសង់ និងដោះស្រាយវិវាទ និង (ខ) កំណត់បទដ្ឋានបច្ចេកទេស ។**

៣) **អប់រំ**: តើគួរមានការអប់រំកម្រិតបរិញ្ញាបត្ររងដែរឬទេ? ដែលការអប់រំកម្រិតនេះស្រូបយកអ្នកប្រលងធ្លាក់សញ្ញាបត្រទុតិយភូមិ។

៤) **កៅស៊ូ**:អ្នកដាំកៅស៊ូនៅកម្ពុជាកំពុងតែប្រឈមនឹងការខាតបង់យ៉ាងខ្លាំង ដោយសារការពឹងផ្អែកលើទីផ្សារនាំចេញតែទៅវៀតណាមប៉ុណ្ណោះ និងមានការបន្ទាបថ្លៃជ័រកៅស៊ូ។ ដូច្នេះគួរមានការធ្វើពិពិធកម្មទីផ្សារនាំចេញនិងក្នុងពេលអនាគត កម្ពុជាគួរមានផលិតកម្មដែលប្រើប្រាស់ជ័រកៅស៊ូកម្ពុជា ដូចជារោងចក្រផលិតសំបកកង់សម្រាប់យានយន្តពូក ស្រោមដៃ ។ល។

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី
## ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
## ប្រចាំខែកញ្ញា ឆ្នាំ២០១៤

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០១/០៩/១៤<br>ម៉ោង ០៧:៣០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីប្រកាសផ្សព្វផ្សាយជាផ្លូវការគោលនយោបាយជាតិ និងផែនការសកម្មភាពជាតិស្ដីពីការគាំពារ និងអភិវឌ្ឍកុមារតូចឆ្នាំ២០១៤-២០១៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត នៅវិទ្យាស្ថានជាតិអប់រំ។ |
| ២ | ០១/០៩/១៤<br>ម៉ោង ១៥:៣០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការព្រលានយន្តហោះ នៅទីស្ដីការគណៈរដ្ឋមន្ត្រី ។ |
| ៣ | ០៤/០៩/១៤<br>ម៉ោង ០៩:០០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយតំណាងក្រុមហ៊ុន Naga World ស្ដីអំពីសំណើសុំពង្រីកបន្ថែមចំណតយន្តហោះនៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ នៅទីស្ដីការគណៈរដ្ឋមន្ត្រី ។ |
| ៤ | ០៤/០៩/១៤<br>ម៉ោង ១៥:៣០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្ដីព្រាងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ២០១៥-២០១៧។<br>២-សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិសម្រាប់វិធានការ មិនមែនពន្ធ។<br>៣-សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនិហិតដ្ឋានជាតិព័ត៌មានពាក់ព័ន្ធនឹង ពាណិជ្ជកម្ម។<br>៤-សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលនាវា ចរណ៍មេគង្គកម្ពុជា។<br>៥-បញ្ហាផ្សេងៗ។ ដើម្បីត្រៀមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទីស្ដីការគណៈរដ្ឋមន្ត្រី ។ |
| ៥ | ០៥/០៩/១៤<br>ម៉ោង ០៨:៣០នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្ដីព្រាងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ២០១៥-២០១៧។<br>២-សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិសម្រាប់វិធានការ មិនមែនពន្ធ។<br>៣-សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនិហិតដ្ឋានជាតិព័ត៌មានពាក់ព័ន្ធនឹង ពាណិជ្ជកម្ម។<br>៤-សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលនាវា ចរណ៍មេគង្គកម្ពុជា។<br>៥-បញ្ហាផ្សេងៗ។ នៅទីស្ដីការនាយករដ្ឋមន្ត្រី។ |

# សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកញ្ញា ឆ្នាំ២០១៤ (ត)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៦ | ០៧/០៩/១៤ ម៉ោង ១៨:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីជប់លៀងរបស់សមាគមអ្នកវិនិយោគចិន ហុងកុង ម៉ាកាវ ក្រោមអធិបតីភាព ដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការ គណៈរដ្ឋមន្ត្រី នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៌កោះពេជ្រ។ |
| ៧ | ០៩/០៩/១៤ ពេញមួយថ្ងៃ | ចូលរួមជាសមាជិកក្នុងកិច្ចប្រជុំការងារ ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការ គណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តតាកែវ នៅសាលប្រជុំ ៧មករា ខេត្តតាកែវ។ |
| ៨ | ១៥/០៩/១៤ ម៉ោង ០៨:៣០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការ ដើម្បីត្រួតពិនិត្យវាយតម្លៃលើការងារបន្ថែមនៃការសាងសង់សំណង់គ្រប់គ្រងទឹកក្នុងតំបន់សៀមរាបអង្គរផ្នែកទី១ និងត្រួតពិនិត្យវាយតម្លៃលើសំណង់ជួសជុលផ្លូវវាងខាងត្បូងក្រុងសៀមរាប ដោយស្រោចកៅស៊ូ ២ស្រទាប់លើកំណាត់ផ្លូវប្រវែង ៣,០១៥គីឡូម៉ែត្រ ក្រោយសុពលភាព នៅសំណង់គ្រប់គ្រងទឹកក្នុងតំបន់សៀមរាបអង្គរផ្នែកទី១។ |
| ៩ | ១៥/០៩/១៤ ម៉ោង ១០:៤០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការ ដើម្បីត្រួតពិនិត្យវាយតម្លៃលើការងារថែទាំផ្លូវវង់តូច និងផ្លូវវង់ធំក្នុងរមណីយ ដ្ឋានអង្គរប្រវែងសរុប ៣១,៥គីឡូម៉ែត្រ ក្រោយសុពលភាព នៅផ្លូវវង់តូច និងផ្លូវវង់ធំក្នុងរមណីយដ្ឋាន អង្គរ ខេត្តសៀមរាប។ |
| ១០ | ១៥/០៩/១៤ ម៉ោង ១៥:០០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការ ដើម្បីត្រួតពិនិត្យវាយតម្លៃលើការងារស្តារ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធ តាមបណ្តោយផ្លូវជាតិលេខ៦ ចាប់ពីភ្លើងស្តុបសណ្ឋាគារសុខាអង្គរ ដល់អាកាសយានដ្ឋានយោធាខេត្ត សៀមរាប នៅខេត្តសៀមរាប។ |
| ១១ | ១៨/០៩/១៤ ម៉ោង ០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រកាសផ្សព្វផ្សាយដាក់ឲ្យប្រើប្រាស់ជាផ្លូវការ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ជាតិ (ផ.យ.អ.ជ) ២០១៤-២០១៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារសូហ្វីតែល ភ្នំពេញភូគីត្រា។ |
| ១២ | ១៨/០៩/១៤ ម៉ោង ១៥:០០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការព្រលានយន្តហោះ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៣ | ២៥/០៩/១៤ ម៉ោង ០៧:៣០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីប្រគល់សញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត ជូនដល់និស្សិត សាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៌កោះពេជ្រ។ |

# សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកញ្ញា ឆ្នាំ២០១៤ (តចប់)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១៤ | ២៥/០៩/១៤ ម៉ោង ១៥:៣០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពីការកំណត់ស្តង់ដាគោលជាតិលីត្រ និងសេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពីការកំណត់ស្តង់ដាគោលជាតិសីតុណ្ហភាព។<br>២-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយ ជាមួយឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៥ | ២៦/០៩/១៤ ម៉ោង ១៦:០០នាទី | ចូលរួមជាកិត្តិយស នៅវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ក្នុងពិធីបំពាក់គ្រឿងឥស្សរិយយសជូនលោក Vincent DEUBEL ប្រធានវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា។ |
| ១៦ | ២៦/០៩/១៤ ម៉ោង ១៨:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីគម្រប់ខួបលើកទី៦៥ឆ្នាំ នៃការបង្កើតសាធារណរដ្ឋប្រជាមានិតចិន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៌កោះពេជ្រ។ |
| ១៧ | ២៩/០៩/១៤ ម៉ោង ០៨:៣០នាទី | ដឹកនាំគណៈកម្មការតាមដាន និងត្រួតពិនិត្យការងារសាងសង់អាកាសយានដ្ឋានអន្តរជាតិ ដើម្បីពិនិត្យ ការសាងសង់ពង្រីកស្ថានីយអ្នកដំណើរនៅអាកាសយានដ្ឋានអន្តរជាតិខេត្តសៀមរាប នៅខេត្តសៀមរាប។ |
| ១៨ | ៣០/០៩/១៤ ម៉ោង ១៦:០០នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការ គណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពីការកំណត់ស្តង់ដាគោលជាតិលីត្រ និងសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការកំណត់ស្តង់ដាគោលជាតិសីតុណ្ហភាព។<br>២-បញ្ហាផ្សេងៗ៖ កិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលស្តីពីផែស្ងួតក្នុងក្របខ័ណ្ឌគណៈកម្មការសេដ្ឋកិច្ចនិងសង្គមសម្រាប់តំបន់អាស៊ីប៉ាស៊ីហ្វិក អង្គការសហប្រជាជាតិ (UNESCAP)។<br>នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

# ព្រឹត្តិបត្រព័ត៌មាន



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in